ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការខេត្តបាត់ដំបង
សំណុំរឿងព្រហ្មទណ្ឌ
លេខ ៧៧៣ ចុះថ្ងៃទី ១៤
ខែ តុលា ឆ្នាំ ២០០៥
សាលក្រម
លេខ ៣៦ ក ចុះថ្ងៃទី ១៧
ខែ កុម្ភៈ ឆ្នាំ ២០០៦

តាមនាមប្រជារាស្ត្រខ្មែរ
តុលាការខេត្តបាត់ដំបង

បានបើកសវនាការជាសាធារណៈ នៅនាទីតុលាការខេត្តបាត់ដំបង នៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៦ ដោយមានសមាសភាពដូចតទៅ :

**ចៅក្រមជំនុំជំរះ**

លោក [redacted] ជាប្រធានតុលាការខេត្តបាត់ដំបង

**តំណាងអយ្យការ** ·

លោក [redacted] ជាព្រះរាជអាជ្ញារង

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

ដើម្បីជំនុំជំរះរឿងក្តីព្រហ្មទណ្ឌលេខ ៧៧៣ ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៥ ដែលមានជនជាប់ចោទ :

១-ឈ្មោះ ហ ម ហៅ ស ភេទប្រុស អាយុ ៤០ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ មានរបរ រកស៊ីថ្ងៃស្រែ មានទីកន្លែងកំណើតនៅភូមិបោះពោធិ ឃុំអូរដំបង១ ស្រុកសង្កែ ខេត្តបាត់ដំបង មានកំរិតវប្បធម៌ថ្នាក់ទី ០៣ថ្មី កាន់សាសនាព្រះពុទ្ធ មានទីលំនៅសព្វថ្ងៃនៅភូមិបោះពោធិ ឃុំអូរដំបង១ ស្រុកសង្កែ ខេត្តបាត់ដំបង មានប្រពន្ធឈ្មោះ ជ ឧ (រ) មានកូន ០១នាក់ មានឪពុកឈ្មោះ ហ ស (ស) មានម្តាយឈ្មោះ ម ម ទោស ពីមុន *គ្មាន* ។

ត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៥ នៅចំណុចផ្ទះរបស់ជនជាប់ចោទនៅភូមិបោះពោធិ ឃុំអូរដំបង១ ស្រុកសង្កែ ខេត្តបាត់ដំបង ។

ត្រូវបានឃុំខ្លួនជាបណ្តោះអាសន្ននៅក្នុងអាគារឃុំខ្លួន នៃពន្ធនាគារខេត្តបាត់ដំបង តាមដីកាឃុំខ្លួនលេខ ៤៨៤ ដឃខ ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៥ ។

ត្រូវជាប់ចោទពីបទ **ជួញដូរគ្រឿងញៀនខុសច្បាប់** ។ តាមបញ្ញត្តិមាត្រា ៣៣ ថ្មី នៃច្បាប់វិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅភូមិបោះពោធិ ឃុំអូរដំបង ស្រុកសង្កែ ខេត្តបាត់ដំបង កាលពីថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៥ ។

**ការប្រព្រឹត្តិរបស់ជនជាប់ចោទមានដូចតទៅ**

កាលពីថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៥ នៅចំណុចភូមិបោះពោធិ ឃុំអូរដំបង ស្រុកសង្កែ ខេត្តបាត់ដំបង ឈ្មោះ ហ ម បានទទួលថ្នាំញៀនចំនួន ១៧គ្រាប់ ពីឈ្មោះ ខ មករក្សាទុក រួចឈ្មោះ ហ ម ធ្វើសកម្មភាពលក់ចែកចាយអោយក្មេងៗក្នុងភូមិបោះពោធិ

CamScanner

ពេលឈ្មោះ ឆ ម កំពុងធ្វើសកម្មភាពលក់ថ្នាំញៀន ក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួន និង ដកហូតថ្នាំញៀននោះតែម្តង ។

-តាមលទ្ធផលកោសល្យវិច្ច័យគ្រឿងញៀនលេខ ២៤/០៦ ម.ព.អ.ជ.ប.ក.ញ ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០៦ ចេញដោយមន្ទីរពិសោធន៍របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានបញ្ជាក់ថា វត្ថុតាងមួយគ្រាប់ពណ៌ទឹកក្រូចពិតជាថ្នាំញៀនហៅ ថ្នាំឆ្កួតមានវត្ថុមានសារធាតុញៀនមេដំហ្វេតាមីន ដែលជាសារធាតុប៉ះពាល់ដល់ប្រព័ន្ធសរសៃប្រសាទស្ថិតក្នុងតារាង២ នៃឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា ។

-តាមដីកាបញ្ជូនរឿងអោយជំនុំជំរះលេខ ១២៦ ៣ស.ព្រទ ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៦ របស់ចៅក្រមស៊ើបអង្កេត បានសំរេចចោទប្រកាន់លើឈ្មោះ ឆ ម ហៅ ស ពីបទជួញដូរគ្រឿងញៀនហាមឃាត់ខុសច្បាប់ ប្រព្រឹត្តនៅភូមិបោះពោធិ ឃុំអូរដំបង១ ស្រុកសង្កែ ខេត្តបាត់ដំបង កាលពីថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៥ មកជំនុំជំរះតាមច្បាប់ ។

## នៅចំពោះមុខតុលាការពេលសវនាការ

ឈ្មោះ ឆ ម ហៅ ស ជាជនជាប់ចោទបានឆ្លើយបញ្ជាក់ថា សមត្ថកិច្ចចាប់ខ្លួនខ្ញុំបាទនៅថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៥ នៅចំណុចផ្ទះរបស់ខ្ញុំបាទស្ថិតក្នុងភូមិបោះពោធិ១ ឃុំអូរដំបង មូលហេតុរឿងខ្ញុំទាក់ទិននឹងថ្នាំញៀនចំនួន ១៧គ្រាប់ ។ ថ្នាំញៀនចំនួន ១៧គ្រាប់ ខ្ញុំបាទបានទទួលពីឈ្មោះ ទ នៅឡែម ស្រុកកំរៀង ក្រោយពីបានទទួលថ្នាំញៀននោះហើយ ខ្ញុំបាទយកមករក្សាទុកនៅផ្ទះក្នុងភូមិបោះពោធិរយៈពេល១២ថ្ងៃ មកដល់ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៥ ខ្ញុំបាទបានយកថ្នាំញៀននោះយកមកលក់អោយពួកក្មេងៗ ក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនតែម្តង ។

## ព្រះរាជអាជ្ញាបានធ្វើសេចក្តីសន្និដ្ឋានថា

មានភស្តុតាង និង ពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ ឆ ម ហៅ ស ពីបទជួញដូរគ្រឿងញៀនខុសច្បាប់ ប្រព្រឹត្តនៅភូមិបោះពោធិ ឃុំអូរដំបង១ ស្រុកសង្កែ ខេត្តបាត់ដំបង កាលពីថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៥ ។

បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសតាមមាត្រា ៣៣ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និង ស្នើសុំអោយតុលាការផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៣ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ស្នើសុំអោយតុលាការផ្តន្ទាទោសកំណត់ពី ០២ឆ្នាំ ដល់ ០៥ឆ្នាំ ។

ឈ្មោះ ឆ ម សុំចៅក្រមបន្ធូរបន្ថយទោស ។

-បានស្តាប់ចម្លើយដោះសាររបស់ជនជាប់ចោទ
-បានស្តាប់ចម្លើយអោយការណ៍របស់សាក្សី
-បានស្តាប់ការសួរដេញដោល ចោទឆ្លើយតទល់
-បានពិនិត្យកំណត់ហេតុ ឯកសារ ភស្តុតាងនានា
-បានស្តាប់សេចក្តីសន្និដ្ឋានចោទប្រកាន់ទោសរបស់តំណាងអយ្យការ
-បានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ
-បានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការខេត្តបាត់ដំបង

CamScanner

## យល់ឃើញថា

-ពិតជាកើតមានឲ្យអំពើរក្សាទុកគ្រឿងញៀនខុសច្បាប់នៅភូមិបោះពោធិ ឃុំអូរដំបង១ ស្រុកសង្កែ កាលពីថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៥ ប្រាកដមែន ។

-អំពើរក្សាគ្រឿងញៀនដែលកើតមាននៅទីកន្លែង និង ពេលវេលាដូចខាងលើពិតជាប្រព្រឹត្តឡើងដោយឈ្មោះ **ឃ ម** ហៅ **ស** ប្រាកដមែន ។

-អំពើដែលឈ្មោះ **ឃ ម** បានប្រព្រឹត្តនៅទីកន្លែង និង ពេលវេលាដូចខាងលើនេះ មានធាតុផ្សំគ្រប់គ្រាន់ជាបទរក្សាទុកគ្រឿងញៀនខុសច្បាប់ពុំមែនបទជួញដូរគ្រឿងញៀនដូចការចោទប្រកាន់ទេ ដូចមានបញ្ញត្តិក្នុងមាត្រា៣៣ថ្មី ត្រង់វាក្យខ័ណ្ឌ១ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដោយថ្នាំញៀនដែលគាត់រក្សាទុកមានតែ ០១គ្រាប់មានទម្ងន់តែ 0.0៩២១ក្រាម ។ ឈ្មោះ **ឃ ម** ជាសមត្ថជនគាត់មានអាយុ ៤០ឆ្នាំមានស្មារតីជានាល្អ គាត់បានប្រព្រឹត្តអំពើដោយចេតនារក្សាទុកថ្នាំញៀនយ៉ាម៉ាចំនួន ០១គ្រាប់ ដោយខុសច្បាប់ ។

## យល់ឃើញថា

-មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ **ឃ ម** ពីបទរក្សាទុកថ្នាំញៀន ប្រព្រឹត្តនៅទីកន្លែង និង ពេលវេលាដូចការចោទប្រកាន់របស់អយ្យការប្រាកដមែន ។

## ភស្តុតាងដាក់បន្ទុកមាន

-ចម្លើយដោះសាររបស់ជនជាប់ចោទបានឆ្លើយបញ្ជាក់យ៉ាងច្បាស់អំពីអំពើដែលខ្លួនបានប្រព្រឹត្តថា ខ្លួនបានទទួលថ្នាំយ៉ាម៉ាចំនួន ១៧គ្រាប់ពីឈ្មោះ **ខ** ភេទស្រី នៅភូមិដូង ឃុំបឹងរាំ ស្រុកកំរៀង បំណងយកមកចាត់ចែងលក់នៅភូមិបោះពោធិ ឃុំអូរដំបង១ ស្រុកសង្កែ ដំបូងមានតែក្មេងឈ្មោះ **ធ** មកសុំទិញ និងបានសន្យាជួយរកម៉ូយមកអោយជួយទិញ បន្ទាប់មកក៏មានមនុស្សប្រុស ០៣នាក់មកសួររកទិញថ្នាំញៀន ខ្លួនក៏បានយកថ្នាំនោះមកអោយពួកគេមើល ស្រាប់តែកំលាំងសមត្ថកិច្ចចាប់ឃាត់ខ្លួនតែម្តង ចម្លើយនេះស៊ីសង្វាក់គ្នាទៅនឹងវត្ថុតាង ដែលដកហូតបានពីជនជាប់ចោទ ។

-វត្ថុតាងមានថ្នាំញៀនយ៉ាម៉ាចំនួន ០១គ្រាប់ពណ៌ទឹកក្រូច និង គ្រាប់ថ្នាំផ្ទុកសារធាតុប៉ារ៉ាសេតាម៉ុល ១៦គ្រាប់គ្មានសារធាតុញៀន ដែលបានមកពីនគរបាលយុត្តិធម៌បានរកឃើញ និង ដកហូតបានពីខ្លួនជនជាប់ចោទឈ្មោះ **ឃ ម** នាពេលឃាត់ខ្លួនក្នុងខណៈនាងកំពុងចាត់ចែងលក់ ហើយត្រូវឃាត់ខ្លួនក្នុងករណីជាបទល្មើសជាក់ស្តែង ។

-លទ្ធផលកោសល្យវិច្ច័យគ្រឿងញៀនលេខ ២៤/០៦ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០៦ ចេញដោយមន្ទីរពិសោធន៍របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានបញ្ជាក់យ៉ាងច្បាស់ពីវត្ថុតាងមួយគ្រាប់ពណ៌ទឹកក្រូចពិតជាថ្នាំញៀនហៅថ្នាំឆ្កួត ដែលមានវត្តមានសារធាតុញៀនមេដំហ្វេតាមីន ដែលជាសារធាតុប៉ះពាល់ប្រពន្ធ័សរសៃប្រសាទស្ថិតក្នុងតារាង ២ នៃឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា ។

-កំណត់ហេតុ ឯកសារ ភស្តុតាងនានា ធ្វើឡើងដោយនគរបាលយុត្តិធម៌ ។

CamScanner

## យល់ឃើញថា

-ឈ្មោះ ហ ម ជនជាប់ចោទមានកិរិតវប្បធម៌ទាប គាត់មានជីវភាពក្រខ្សត់ គាត់ជាជនមិនធ្លាប់មានទោសពីមុនមក កម្មវត្ថុនៃបទល្មើសមានថ្នាំញៀនតែ ០១គ្រាប់ប៉ុណ្ណោះ ស្ថានភាពទាំងនេះអាចអោយតុលាការយកមកពិចារណាជាស្ថានសម្រាលទោសអោយគាត់បាន ។

-វត្ថុតាងទាំងអស់ត្រូវបានដកហូតសំណាកយកទៅធ្វើកោសល្យវិច្ឆ័យអស់ហើយ ។

## ហេតុដូច្នេះតុលាការវិនិច្ឆ័យសេចក្តី

១-ផ្តន្ទាទោសឈ្មោះ ហ ម ហៅ ស ដាក់ពន្ធនាគារកំណត់ ០២ឆ្នាំគត់ ដោយគិតចាប់ពីថ្ងៃឃុំខ្លួនថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៥ ។

ពីបទ **រក្សាទុកគ្រឿងញៀនដោយខុសច្បាប់** ប្រព្រឹត្តនៅភូមិបោះពោធិ ឃុំអូរដំបង១ ស្រុកសង្កែ ខេត្តបាត់ដំបង កាលពីថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៥ ។

បទល្មើសព្រហ្មទណ្ឌ ទណ្ឌកម្ម និង ការផ្តន្ទាទោសមានបញ្ញត្តិក្នុងមាត្រា ៣៣ ត្រង់វាក្យខណ្ឌ ១ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលបានប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស/រកម/ ០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ។

២-សាលក្រមនេះ ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ ។ បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់រយៈពេល ០២ខែ គិតចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

**ក្រឡាបញ្ជីសវនាការ**

[redacted]

**ចៅក្រមជំនុំជំរះ**

[redacted]

---

ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកអ្នកអនុវត្តសាលក្រមអោយសំរេចតាមសាលក្រមនេះ និង អោយអាជ្ញាធរគ្រប់តំណែង គ្រប់ជាន់ថ្នាក់ ជួយអនុវត្តអោយបានសំរេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

*បាត់ដំបង, ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០០៦*

**ជ.ក្រឡាបញ្ជីសវនាការ**

[redacted]

**បានឃើញ**

*បាត់ដំបង, ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០០៦*

**ប្រធានតុលាការខេត្ត**

[redacted]

CS CamScanner